សាលារៀននៅឡុងប៊ីច LBUSD នឹងបង្រៀនតាមអនឡាញទាំងស្រុងនៅពេលចាប់ផ្តើមឆ្នាំសិក្សាថ្មី

នៅពេលឆ្នាំសិក្សាថ្មីចាប់ផ្តើមនៅថ្ងៃទី១ខែកញ្ញា ថ្នាក់រៀនទាំងអស់នៅក្នុងក្រសួងអប់រំឡុងប៊ីចនឹងបង្រៀនតាមរយៈអនឡាញទាំងស្រុង យ៉ាងឆាប់ណាស់ក៏រហូតដល់ថ្ងៃទី៥ខែតុលាដែរ ដោយសារតែការកើនឡើងយ៉ាងខ្ពស់នៃករណីវីរុសកូរ៉ូណានៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា។

ក្រសួងអប់រំនៅតែបន្តរៀបចំគ្រោងសម្រាប់ការបង្រៀនផ្ទាល់ជាធម្មតានិងវិធានការសុវត្ថិភាពនានាសម្រាប់អនាគតកាលខាងមុខនេះ។ ការសម្រេចចិត្តក្នុងសប្តាហ៍នេះថាចាប់ផ្តើមឆ្នាំសិក្សាថ្មីតាមរយៈអនឡាញទាំងស្រុងគឺត្រូវបានធ្វើឡើងបន្ទាប់ពីបានពិភាក្សាគ្នាយ៉ាងជិតដល់ជាមួយមន្ត្រីសុខភាពក្នុងតំបន់ ដែលមានទាំងវេជ្ជៈបណ្ឌិត Anissa Davis មន្ត្រីសុខភាពនៅក្រសួងសុខាភិបាលនិងធនធានមនុស្សប្រចាំឡុងប៊ីច ហើយនិងវេជ្ជៈបណ្ឌិត Barbara Ferrer មន្ត្រីសុខភាពនៅក្រសួងសុខាភិបាលប្រចាំខោនធីឡូសអិនជើលេស។

"វីរុសកូរ៉ូណាកំពុងតែលុកលុយសហគមន៍យើងយ៉ាងខ្លាំង ដូច្នេះយើងត្រូវបន្តប្រឹងប្រែងអស់ពីសមត្ថិភាពដើម្បីការពារកូនចៅយើង គ្រូបង្រៀនយើង និងមនុស្សដ៏សំខាន់ៗជាច្រើនដែលជាអ្នកធ្វើឱ្យសាលារៀនមានដំណើរការនិងផ្តល់ការបង្ហាត់បង្រៀនដល់កូនចៅយើង" បណ្ឌិត Ferrer បានមានប្រសាសន៍នៅក្នុងពិធីសន្និសិទកាលពីម្សិលមិញ។

ទោះបីជាក្រសួងអប់រំឡុងប៊ីចបានមានសង្ឃឹមថានឹងអាចអនុញ្ញាតឱ្យមាតាបិតាជ្រើសរើសកម្មវិធីសិក្សាដែលបង្រៀនតាមរយៈអនឡាញទាំងស្រុងឬការសិក្សាតាមរយៈអនឡាញខ្លះនិងជួបគ្នាផ្ទាល់ខ្លះ សម្រាប់ឆ្នាំសិក្សាថ្មីនៅថ្ងៃទី១ខែកញ្ញានេះ ក៏ប៉ុន្តែផែនការនេះត្រូវផ្អាកទុកសិន ដោយយើងនឹងជ្រើសរើសការសិក្សាតាមរយៈអនឡាញទាំងស្រុងវិញសម្រាប់សិស្សរាល់គ្នា។ ចំពោះមាតាបិតា នេះគឺមានន័យថា គាត់មិនចាំបាច់ជ្រើសរើសកម្មវិធីសិក្សាសម្រាប់កូនគាត់ទេ យ៉ាងហោចណាស់នៅក្នុងរយៈពេលប៉ុន្មានសប្តាហ៍ដំបូងនៃឆ្នាំសិក្សាថ្មី។ នៅក្នុងពេលដែលសាលាបិទទ្វារនេះ ក្រសួងអប់រំឡុងប៊ីចនឹងបន្តផ្តល់សេវាកម្មមើលថែកុមារដែលបានរៀបចំគ្រោងតាមរយៈមណ្ឌលបណ្តុះបណ្តាលកុមារនិងហ៊ែដស្តាត ដោយមានការប្រុងប្រយ័ត្នដែលចាំបាច់ទាំងអស់នៅនឹងកន្លែង។

ក្រសួងអប់រំឡុងប៊ីច LBUSD នឹងបន្តសហការជាមួយសមាគមគ្រូបង្រៀននិងក្រុមបុគ្គលិកផ្សេងៗទៀត ព្រមទាំងមន្ត្រីសុខភាពនានាផងដែរ អំពីការស្វែងរកវិធីដែលប្រសើរជាងគេក្នុងការបង្រៀននិងការរៀនសូត្រ ខណៈដែលការបញ្ជាក់នូវសុខភាពនិងសុវត្ថិភាពនៅតែជាអាទិភាពខ្ពស់ជាងគេរបស់យើង។ ក្រសួងអប់រំនឹងបន្តធ្វើការទាក់ទងដល់មាតាបិតាតាមរបៀបផ្សេងៗ នៅថ្ងៃនិងសប្តាហ៍ជាបន្តបន្ទាប់ខាងមុខនេះ ដែលមានរួមទាំងតាមរយៈគេហទំព័ររបស់ក្រសួងអប់រំនៅ lbschools.net , តាមរយៈគេហទំព័ររបស់សាលារៀននីមួយៗ តាមអ៊ីមែល តាមសារទូរស័ព្ទ និងតាមរយៈបណ្តាញសង្គម។

សូមចូលទៅវែបសាយ lbschools.net/coronavirus ដើម្បីរកមើលព័ត៌មានបច្ចុប្បន្នភាព។